# Disability Medical Assessment (ការវាយតម្លៃផ្នែកវេជ្ជសាស្ត្រលើជនពិការ)

## តើអ្វីជា Disability Medical Assessment (DMA)?

DMA គឺជាការវាយតម្លៃឥតគិតថ្លៃមួយដែលជួយ Services Australia (សេវាកម្មអូស្ត្រាលី) សម្រេចចិត្តថាតើអ្នកបំពេញតាមច្បាប់វេជ្ជសាស្ត្រសម្រាប់ Disability Support Pension (ប្រាក់សោធននិវត្តន៍សម្រាប់ជនពិការ) (DSP) ដែរឬទេ។

Government-contracted Doctor (វេជ្ជបណ្ឌិតដែលជាប់កិច្ចសន្យាដោយរដ្ឋាភិបាល) មកពី Sonic HealthPlus នឹងធ្វើ DMA។ Government-contracted Doctor អាចជាវេជ្ជបណ្ឌិត ឬ Clinical Psychologist (អ្នកចិត្តសាស្ត្រគ្លីនិក)។

Government-contracted Doctor ពិនិត្យមើលភស្តុតាងវេជ្ជសាស្ត្ររបស់អ្នក ហើយសរសេររបាយការណ៍អំពីរបៀបដែលស្ថានភាពរបស់អ្នកប៉ះពាល់ដល់អ្នក។

ពួកគេអាចទាក់ទងវេជ្ជបណ្ឌិត និងអ្នកជំនាញផ្នែកសុខភាពដែលកំពុងព្យាបាលអ្នក ដើម្បីនិយាយអំពីព័ត៌មានដែលអ្នកបានផ្តល់ជាភស្តុតាងវេជ្ជសាស្ត្រ។

Government-contracted Doctor នឹងរក្សាព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកដោយសុវត្ថិភាព និងការពារសិទ្ធិឯកជនភាពរបស់អ្នក។

## តើ DMA របស់អ្នកនឹងត្រូវបានធ្វើឡើងយ៉ាងដូចម្តេច?

DMA របស់អ្នកអាចត្រូវបានធ្វើដោយផ្ទាល់នៅគ្លីនិក Sonic HealthPlus តាមសន្និសីទតាមវីដេអូ ឬតាមទូរសព្ទ។ ពួកគេអាចកក់អ្នកបកប្រែផ្ទាល់មាត់ដើម្បីជួយអ្នកក្នុងការវាយតម្លៃរបស់អ្នក។

Sonic HealthPlus នឹងទូរសព្ទទៅអ្នក ហើយផ្ញើលិខិតមួយច្បាប់អំពីការណាត់ជួបរបស់អ្នក និងរបៀបដែល DMA របស់អ្នកនឹងត្រូវបានធ្វើឡើង។ វាអាចរួមបញ្ចូលតំណសន្និសីទតាមវីដេអូដែលអ្នកអាចភ្ជាប់ ឬអាសយដ្ឋានគ្លីនិក Sonic HealthPlus។

ប្រសិនបើ DMA របស់អ្នកនឹងត្រូវបានធ្វើឡើងតាមទូរសព្ទ Government-contracted Doctor នឹងទូរសព្ទមកអ្នក តាមលេខទូរសព្ទដែលអ្នកបានផ្តល់ឱ្យពួកគេ។

DMA ក៏អាចត្រូវបានធ្វើឡើងដោយផ្ទាល់ជាមួយ Treating Health Professional (អ្នកជំនាញផ្នែកសុខភាពដែលផ្តល់ការព្យាបាល) របស់អ្នកផងដែរ។ អ្នកប្រហែលជាមិនចាំបាច់ចូលរួមទេ។

## ប្រសិនបើអ្នកមិនអាចចូលរួម DMA របស់អ្នកបានទេ

ប្រសិនបើអ្នកឈឺ ឬមិនអាចចូលរួមការវាយតម្លៃរបស់អ្នកបានទេ អ្នកអាចទូរសព្ទដើម្បីធ្វើការណាត់ជួបថ្មីមួយ។

ទូរសព្ទទៅ Sonic HealthPlus តាមលេខ **1300 295 822** ដើម្បីធ្វើការណាត់ជួបថ្មីមួយ។

## អ្វីដែលត្រូវយកមកកាន់ DMA របស់អ្នក

សម្រាប់ការវាយតម្លៃ សូមយក៖

- ឯកសារមួយច្បាប់ដើម្បីបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នក ឧទាហរណ៍ driver licence (ប័ណ្ណបើកបរ) ឬ Australian passport (លិខិតឆ្លងដែនអូស្ត្រាលី) របស់អ្នក។

- ជំនួយ ឧបករណ៍ ឬឧបករណ៍បច្ចេកវិទ្យាជំនួយណាមួយដែលអ្នកប្រើ ដូចជាឧបករណ៍ជំនួយការស្តាប់ ឬការមើលឃើញជាដើម។

អ្នកក៏អាចនាំយកសាច់ញាតិ មិត្តភក្តិ អ្នកតស៊ូមតិ ឬ correspondence nominee (អ្នកតែងតាំងសរសេរទាក់ទងគ្នា) របស់អ្នកដើម្បីគាំទ្រផងដែរ។

អ្នកមិនចាំបាច់នាំយកព័ត៌មានដែលអ្នកបានផ្តល់ទៅឱ្យ Services Australia រួចហើយ សម្រាប់ការទាមទារ ឬការពិនិត្យរបស់អ្នកនោះទេ។

អ្នកត្រូវតែផ្តល់ភស្តុតាងវេជ្ជសាស្ត្រថ្មីណាមួយដល់ Services Australia មុនការណាត់ជួប DMA របស់អ្នកជាមួយ Sonic HealthPlus។ អ្នកអាចផ្ទុកឡើងឯកសារនានាតាមរយៈគណនីអនឡាញ Centrelink របស់អ្នក ឬ កម្មវិធីទូរសព្ទ Express Plus Centrelink mobile app។ អ្នកក៏អាចផ្តល់ឯកសារទាំងនេះទៅឱ្យ Services Australia តាមសំបុត្រ ទូរសារ ឬដោយការអញ្ជើញទៅកាន់មជ្ឈមណ្ឌលសេវាកម្មមួយ។

## តើមានអ្វីកើតឡើងបន្ទាប់ពី DMA របស់អ្នក?

បន្ទាប់ពី DMA របស់អ្នក Government-contracted Doctor នឹងផ្ញើរបាយការណ៍មួយទៅឱ្យ Services Australia។ Services Australia ប្រើរបាយការណ៍នោះដើម្បីជួយពួកគេវាយតម្លៃការទាមទារ ឬបណ្តឹងឧទ្ធរណ៍ DSP របស់អ្នក។

Services Australia នឹងសរសេរដើម្បីប្រាប់អ្នកអំពីលទ្ធផលនៃការទាមទារ ឬបណ្តឹងឧទ្ធរណ៍របស់អ្នក។

## ទាក់ទង Services Australia

ប្រសិនបើអ្នកមានសំណួរ ឬកង្វល់ណាមួយអំពី DMA ឬវឌ្ឍនភាពនៃការទាមទារ DSP របស់អ្នក ឬប្រសិនបើអ្នកចង់ទទួលបានច្បាប់ចម្លងនៃរបាយការណ៍ DMA សូមទូរសព្ទទៅ  Disability, sickness and carers line (បណ្តាញទូរសព្ទជនពិការ ជំងឺ និងអ្នកថែទាំ) តាមលេខ **132 717**។ សូមកុំទាក់ទង Sonic HealthPlus ដោយផ្ទាល់។

Services Australia នឹងប្រាប់អ្នក ប្រសិនបើអ្នកចាំបាច់ត្រូវដាក់សំណើ  Freedom of Information (សេរីភាព ដើម្បីទទួលបានព័ត៌មាន) (FOI) ជាផ្លូវការមួយ។ សូមចូលទៅកាន់ **servicesaustralia.gov.au/foi** សម្រាប់ ព័ត៌មានបន្ថែមអំពី FOI។

ចូលទៅកាន់ **servicesaustralia.gov.au/feedback** ឬហៅទូរសព្ទលេខ **1800 132 468** ដើម្បីផ្តល់មតិកែលម្អ ឬធ្វើបណ្តឹងតវ៉ា។

## សម្រាប់ព័ត៌មានបន្ថែម

- សូមចូលទៅកាន់ servicesaustralia.gov.au/dspmedicalassessment សម្រាប់ព័ត៌មានបន្ថែមជាភាសាអង់គ្លេស។
- ទូរសព្ទទៅ Disability, sickness and carers line តាមលេខ **132 717**។ សូមអនុញ្ញាតឱ្យពួកយើងដឹង ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ហើយយើងនឹងរៀបចំជូនអ្នកដោយឥតគិតថ្លៃ។
- ព័ត៌មានមួយចំនួនមានជាសម្លេង ស៊ីឌី/ឌីវីឌី ការបោះពុម្ពជាអក្សរធំ អក្សរស្ទាបសម្រាប់មនុស្សខ្វាក់ និងអត្ថបទអានជាទម្រង់ឌីជីថល។ អ្នកអាចស្នើសុំព័ត៌មានទាំងនេះដោយទូរសព្ទទៅ Disability, sickness and carers line តាមលេខ **132 717**។
- ចូលទៅកាន់ servicesaustralia.gov.au/yourlanguage ជាកន្លែងដែលអ្នកអាចអាន ស្តាប់ ឬមើលព័ត៌មានជាភាសារបស់អ្នក។
- ទូរសព្ទទៅ **131 202** ដើម្បីនិយាយជាមួយយើងជាភាសារបស់អ្នក អំពីប្រាក់ឧបត្ថម្ភ និងសេវាកម្មនានារបស់ Centrelink។

- ហៅទូរសព្ទលេខ **132 011** សម្រាប់ Medicare និងលេខ **131 272** សម្រាប់  Child Support (ការផ្គត់ផ្គង់កុមារ)។ សូមអនុញ្ញាតឱ្យពួកយើងដឹង ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ហើយយើងនឹងរៀបចំជូនអ្នកដោយឥតគិតថ្លៃ។
- អញ្ជើញទៅកាន់មជ្ឈមណ្ឌលសេវាកម្ម។

ប្រសិនបើអ្នកថ្លង់ ឬមានពិការភាពក្នុងការស្តាប់ ឬការនិយាយ អ្នកអាចៈ

- ហៅទូរសព្ទ TTY* តាមលេខ **1800 810 586**
- ប្រើ **relayservice.gov.au**

*TTY គឺសម្រាប់តែមនុស្សថ្លង់ ឬអ្នកដែលមានពិការភាពក្នុងការស្តាប់ ឬការនិយាយប៉ុណ្ណោះ។ ត្រូវការទូរសព្ទ TTY ដើម្បីប្រើប្រាស់សេវាកម្មនេះ។

ចំណាំៈ ការហៅទូរសព្ទពីទូរសព្ទរបស់អ្នកទៅលេខ '13' ពីកន្លែងណាមួយនៅក្នុងប្រទេសអូស្ត្រាលី នឹងត្រូវបង់ថ្លៃតាមអត្រាថេរ។ អត្រានេះអាចខុសគ្នាពីអត្រាហៅទូរសព្ទនៅតាមតំបន់ និងរវាងក្រុមហ៊ុនផ្តល់សេវាកម្មទូរសព្ទនានា។ ការហៅទូរសព្ទទៅលេខ '1800' ពីទូរសព្ទផ្ទះរបស់អ្នកគឺមិនគិតថ្លៃទេ។ ការហៅទូរសព្ទពីទូរសព្ទសាធារណៈ និងទូរសព្ទដៃ អាចគិតថ្លៃតាមពេលម៉ោងហៅ ហើយគិតថ្លៃតាមអត្រាខ្ពស់ជាង។

## ការបដិសេធ

ព័ត៌មានដែលមាននៅក្នុងការបោះពុម្ពផ្សាយនេះ គឺមានគោលបំណងត្រឹមតែជាការណែនាំអំពីការទូទាត់ និងសេវាកម្មប៉ុណ្ណោះ។ វាជាទំនួលខុសត្រូវរបស់អ្នកក្នុងការសម្រេចចិត្តថាតើអ្នកចង់ដាក់ពាក្យសុំប្រាក់ឧបត្ថម្ភ និងធ្វើការដាក់ពាក្យឬអត់ ទាក់ទងនឹងកាលៈទេសៈជាក់លាក់របស់អ្នក។

# Disability Medical Assessment

## What is a Disability Medical Assessment (DMA)?

A DMA is a free assessment that helps Services Australia decide if you meet the medical rules for the Disability Support Pension (DSP).

A Government-contracted Doctor from Sonic HealthPlus will do the DMA. The Government-contracted Doctor can be a doctor or a Clinical Psychologist.

The Government-contracted Doctor reviews your medical evidence and writes a report about how your condition affects you.

They may contact the doctors and health professionals treating you, to talk about the information you gave as medical evidence.

The Government-contracted Doctor will keep your personal information safe and protect your right to privacy.

## How will your DMA be done?

Your DMA may be done in person at a Sonic HealthPlus clinic, by video conference or telephone. They can book an interpreter to help you at your assessment.

Sonic HealthPlus will call you and send you a letter about your appointment and how your DMA will be done. It may include a video conference link you can connect to or the Sonic HealthPlus clinic address.

If your DMA will be done over the telephone, the Government-contracted Doctor will call you on the phone number you gave them.

The DMA may also be done directly with your Treating Health Professional. You may not need to attend.

## If you cannot attend your DMA

If you are sick or cannot attend your assessment, you can call to make a new appointment.
Call Sonic HealthPlus on **1300 295 822** to make a new appointment.

## What to bring to your DMA

For the assessment please bring:

- a document to confirm your identity for example your driver licence or Australian passport.
- any aids, equipment or assistive technology you use, such as hearing or visual aids.

You can also bring a relative, friend, an advocate or your correspondence nominee for support.

You do not need to bring information you have already given to Services Australia for your claim or review.

You must give any new medical evidence to Services Australia before your DMA appointment with Sonic HealthPlus. You can upload documents through your Centrelink online account or the Express Plus Centrelink mobile app. You can also give them to Services Australia by mail, fax, or by visiting a service centre.

## What happens after your DMA?

After your DMA, the Government-contracted Doctor will send Services Australia a report. Services Australia use the report to help them assess your DSP claim or appeal.

Services Australia will write to tell you the result of your claim or appeal.

## Contact Services Australia

If you have any questions or concerns about the DMA or progress of your DSP claim, or if you would like a copy of the DMA report, call the Disability, sickness and carers line on **132 717**. Do not contact Sonic HealthPlus directly.

Services Australia will let you know if you need to make a formal Freedom of Information (FOI) request. Go to **servicesaustralia.gov.au/foi** for more information about FOI.

Go to **servicesaustralia.gov.au/feedback** or call **1800 132 468** to provide feedback or make a complaint.

## For more information

- Go to servicesaustralia.gov.au/dspmedicalassessment for more information in English.
- Call the Disability, sickness and carers line on **132 717**. Let us know if you need an interpreter, and we will arrange one for free.
- Some information is available in audio, CD/DVD, large print, braille and e-text. You can ask for these by calling the Disability, sickness and carers line on **132 717**.
- Go to **servicesaustralia.gov.au/yourlanguage** where you can read, listen to or watch information in your language.
- Call **131 202** to speak with us in your language about Centrelink payments and services.
- Call **132 011** for Medicare and **131 272** for Child Support. Let us know if you need an interpreter, and we will arrange one for free.
- Visit a service centre.

If you're deaf or have a hearing or speech impairment, you can either:

- call TTY* on **1800 810 586**
- use **relayservice.gov.au**

*TTY is only for people who are deaf or who have a hearing or speech impairment. A TTY phone is required to use this service.

Note: calls from your phone to '13' numbers from anywhere in Australia are charged at a fixed rate. That rate may vary from the price of a local call and may also vary between telephone service providers. Calls to '1800' numbers from your home phone are free. Calls from public and mobile phones may be timed and charged at a higher rate.

## Disclaimer

The information contained in this publication is intended only as a guide to payments and services. It's your responsibility to decide if you wish to apply for a payment and to make an application with regard to your particular circumstances.